តុលាការខេត្តបាត់ដំបង

រឿងព្រហ្មទណ្ឌ

លេខ ៨២១ ចុះថ្ងៃទី ១១

ខែ វិច្ឆិកា ឆ្នាំ ២០០៤

សាលក្រមព្រហ្មទណ្ឌ

លេខ ៨៦ "ក" ចុះថ្ងៃទី ១១

ខែ មេសា ឆ្នាំ ២០០៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាមឈ្មោះប្រជារាស្ត្រខ្មែរ**

**តុលាការខេត្តបាត់ដំបង**

បានបើកសវនាការជាសាធារណៈនៅទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៧ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងតុលាការខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

ក [redacted]

ដើម្បីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌលេខ ៨២១ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទ :

១-ឈ្មោះ [redacted] ភេទប្រុស អាយុ ៤៦ ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបរកស៊ីរត់ឡានឈ្នួល មានទីកន្លែងកំណើតនៅភូមិវត្តកណ្តាល ឃុំស្វាយចាំ ស្រុកសង្កែ ខេត្តបាត់ដំបង ។ មានកំរិតវប្បធម៌ ថ្នាក់ទី ៣ ចាស់ កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិអូរនា ឃុំអូរនា ស្រុកសង្កែ ខេត្តបាត់ដំបង មានប្រពន្ធឈ្មោះ [redacted] " មានកូន ០៥ នាក់ មានឪពុកឈ្មោះ [redacted] " ស " មានម្តាយឈ្មោះ [redacted] ស " ទោសពីមុន គ្មាន ។

២- ឈ្មោះ [redacted] ភេទស្រី អាយុ ៤១ ឆ្នាំ ជាតិឥស្លាម សញ្ជាតិខ្មែរ របរកស៊ី គ្មាន កើតនៅភូមិអូរនា ឃុំអូរនា ស្រុកសង្កែ ខេត្តបាត់ដំបង កំរិតវប្បធម៌ មិនចេះអក្សរ កាន់សាសនាមហាម៉ាត់ ទីលំនៅសព្វថ្ងៃភូមិអូរនា ឃុំអូរនា ស្រុកសង្កែ ខេត្តបាត់ដំបង មានប្តីឈ្មោះ [redacted] រ " មានកូន ០៥ នាក់ ឪពុកឈ្មោះ [redacted] " ស " ម្តាយឈ្មោះ [redacted] ង " ទោសពីមុនធ្លាប់មានទោសព្យួរ ១០ ខែ ។

៣- ឈ្មោះ [redacted] ភេទស្រី អាយុ ១៩ ឆ្នាំ ជនជាតិខ្មែរឥស្លាម របរកស៊ី គ្មាន កើតនៅភូមិអូរនា ឃុំអូរនា ស្រុកសង្កែ ខេត្តបាត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៩ ថ្មី កាន់សាសនាមហាម៉ាត់ មានទីលំនៅសព្វថ្ងៃភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ [redacted] " រ " ម្តាយឈ្មោះ [redacted] រ " ទោសពីមុនគ្មាន ។

៤- ឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ ជនជាតិខ្មែរឥស្លាម របរកស៊ី គ្មាន កើតនៅភូមិអូរនា ឃុំអូរនា ស្រុកសង្កែ ខេត្តបាត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៩ ថ្មី កាន់សាសនាមហាម៉ាត់ មានទីលំនៅសព្វថ្ងៃភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ [redacted] " រ " ម្តាយឈ្មោះ [redacted] " រ " ទោសពីមុនគ្មាន



Scanned by CamScanner

៥- ឈ្មោះ [redacted] ភេទស្រី អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី លក់គ្រឿងក្មេង កើតនៅភូមិព្រៃដាច់ ឃុំអូរតាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង កំរិតវប្បធម៌ គ្មាន កាន់សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិចំការ សំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ [redacted] រ ម្តាយ ឈ្មោះ [redacted] ទោសពីមុនគ្មាន ។

៦- ឈ្មោះ [redacted] ហៅ ពៅ ភេទស្រី អាយុ ៣២ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី គ្មាន កើតនៅភូមិអូរចារ ឃុំជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៨ ថ្មី កាន់សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានប្តីឈ្មោ[redacted] មានកូន ០៣ នាក់ មានឪពុកឈ្មោ[redacted] រ ម្តាយ ឈ្មោ[redacted] រ ទោសពីមុនគ្មាន ។

៧- ឈ្មោះ [redacted] ហៅ[redacted] ភេទប្រុស អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី ជាងមាស និងរត់ម៉ូតូឌុប កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កំរិតវប្បធម៌ សញ្ញាប័ត្រ បឋមភូមិ កាន់សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានប្រពន្ធឈ្មោ[redacted] រ មានកូន ០៣ នាក់ មានឪពុកឈ្មោះ[redacted] រ ម្តាឈ្មោះ [redacted] រ ទោសពីមុនគ្មាន ។

៨- ឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី រៀនកែសម្ផស្ស កើតនៅភូមិចំការសំរោង ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៣ ថ្មី កាន់សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ[redacted] ស ម្តាយ ឈ្មោ[redacted] ស ទោសពីមុនគ្មាន ។

៩- ឈ្មោះ [redacted] ភេទស្រី អាយុ ១៨ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី នៅផ្ទះ កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង កំរិតវប្បធម៌ អត់ចេះអក្សរ កាន់សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ[redacted] ស ម្តាយ ឈ្មោះ[redacted] ស ទោសពីមុនគ្មាន ។

១០- ឈ្មោះ[redacted] ភេទប្រុស អាយុ ១៧ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី ជាងម៉ាស៊ីន កើតនៅភូមិ ផ្កាស្លា ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៥ ថ្មី កាន់សាសនា ព្រះពុទ្ធ ទីលំនៅ-សព្វថ្ងៃភូមិ ព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ[redacted] ស ម្តាយ ឈ្មោ[redacted] ស ទោសពីមុនគ្មាន ។

ជនជាប់ចោទជាប់ចោទពីបទបង្ករបួសដោយចេតនាមានអាវុធ និងជេរប្រមាថ ប្រព្រឹត្តនៅ-ភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ និង ៦៣ នៃច្បាប់ព្រហ្ម-ទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>

- ឈ្មោះ[redacted] ភេទប្រុស អាយុ ៤៦ ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិនរា ឃុំនរា ស្រុក



Scanned by CamScanner

សង្កែ ខេត្តបាត់ដំបង ។

ក្នុងរឿងនេះខ្លួនជំនួសមុខប្រពន្ធ និងកូនសុំប្តឹងទាមទារសំណងព្យាបាល និងជម្ងឺចិត្ត រួមទាំងការបាត់បង់គ្រឿងអលង្ការរបស់កូនសរុបចំនួន ៧.០០០.០០០៛ ( ប្រាំពីរលានរៀលគត់ ) ហើយជនល្មើសប្រគល់ជូន-តុលាការសំរេចតាមច្បាប់ ។

- ឈ្មោះ [redacted] ប [redacted] ភេទស្រី អាយុ ៣២ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងព្យាបាល និងជម្ងឺចិត្តសរុបទាំងការបាត់បង់របស់ចំនួន - ២.០០០ ដុល្លា ( ពីរពាន់ដុល្លាអាមេរិក ) ចំណែកជនល្មើសសុំអោយតុលាការផ្តន្ទាទោសទៅតាមច្បាប់ ។

- ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៧ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំ បង

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងព្យាបាលរបួស និងជម្ងឺចិត្តសរុបចំនួន ២.០០០ ដុល្លា ( ពីរពាន់ដុល្លាអាមេរិក ) ឯជនល្មើសសុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ ។

- ឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយ-ប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងព្យាបាល សំណងអង្គកាយ និងជម្ងឺចិត្តសរុប ៥.០០០ ដុល្លា ( ប្រាំពាន់ដុល្លាអាមេរិក ) ឯជនល្មើសសុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ ។

- ឈ្មោះ [redacted] ភេទស្រី អាយុ ១៨ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងជម្ងឺចិត្ត និងថ្លៃព្យាបាលជម្ងឺចំនួន ៣០.០០០ បាត ( បីម៉ឺនបាតគត់ ) បើគ្មានប្រាក់សងទេ សុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ ។

- ឈ្មោ[redacted] ភេទស្រី អាយុ ៣២ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិអូរតាគាំ២ ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ខ្លួនសុំសំណូមពរ សុំទាមទារថ្លៃសំណងកិត្តិយស និងសំណងជម្ងឺចិត្តសរុប ១០.០០០.០០០៛ ( ដប់លានរៀលគត់ ) ឯជនល្មើសសុំអោយតុលាការធ្វើការឃុំខ្លួន និងសំរេចទៅតាមផ្លូវច្បាប់ ។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៨៦ ជសសព ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តបាត់ដំបង ។

- បានឃើញដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ១០៣២ ពសព្រព ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្តបាត់ដំបង ។

ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៥ វេលាម៉ោង ១០ និង៣០នាទីយប់ មានជនល្មើសពីរក្រុម ក្រុមទី ១ មានឈ្មោះ [redacted] ភេទប្រុស .២- [redacted] ភេទស្រី . ៣ [redacted] ភេទស្រី .៤-[redacted]

ភេទស្រី និង [redacted] ភេទប្រុស . ក្រុមទី២ មានឈ្មោះ :១- [redacted] ហៅ ពៅ ភេទស្រី . ២- [redacted] ភេទប្រុស .៣- [redacted] ភេទស្រី .៤- [redacted] ភេទស្រី និង [redacted] ភេទប្រុស បានជេរ ប្រមាថ និងវាយគ្នាទៅវិញទៅមកបណ្ដាលអោយរងគ្រោះទាំងសងខាង ។

**ចាប់ផ្ដើមសវនាការ**

- ជនជាប់ចោទ និងជាដើមបណ្ដឹងឈ្មោះ [redacted] បានឆ្លើយថា : កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោងប្រហែល ៩ ទៅ ១០ យប់ ពេលនោះ ខ្លួនបានទៅហៅក្មួយឈ្មោះ [redacted] មកផ្ទះ ព្រោះរៀបចំហូបបាយ ពេលទៅហៅត្រឡប់មកវិញហូបបាយបានពីរមាត់ស្រាប់ តែឈ្មោះ [redacted] ទាញខ្លួន ចេញ ហើយវាយខ្លួន និងដៃ ហើយមានបុរសពីរនាក់ទៀតបានវាយខ្លួន និងឃើញឈ្មោះ [redacted] ដេក- ហើយមានកូនស្រីរបស់គាត់ និងស្រីខារ៉ាអូខេបានមកវាយខ្លួន និងប្រពន្ធ និងក្មួយ ក្រោយមកកូនគាត់បានគប់ កែវចូលក្នុងផ្ទះខ្លួនទៀត ពេលនោះខ្លួនមិនបានវាយទៅលើគេវិញទេ ដោយខ្លួនមានឈ្មោះ [redacted] [redacted] ជាសាក្សី ព្រោះគាត់នៅជិតផ្ទះខ្លួនដោយគាត់បានចេញមកឃាត់ កន្លងមកមិនធ្លាប់មានទំនាស់អ្វីទេ ។

នៅពេលនេះខ្លួនសុំទាមទារថ្លៃព្យាបាល និងជំងឺចិត្តពីរនៃ ណារ៉ូ ចំនួន ១.០០០.០០០៖០០ ( មួយលានរៀល ) ។

ខាងខ្លួនជាជនរងគ្រោះ មិនចង់ប្ដឹងតទៅទៀតទេ គ្រាន់តែសុំថ្លៃព្យាបាលក្មួយខ្លះអោយសមរម្យ គឺចំនួន ២.០០០.០០០៖០០ ( ពីរលានរៀល ) ។

- ជនជាប់ចោទ និងជាដើមបណ្ដឹងឈ្មោះ [redacted] បានឆ្លើយថា : នៅថ្ងៃកើតហេតុថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោងដប់ និងសាមសិបនាទីយប់ ពេលខ្លួនបើកទ្វារចេញស្រាប់តែឈ្មោះ [redacted] និង កូនគាត់ពីរនាក់ទៀត ឈ្មោះ [redacted] មកជិះលើខ្លួន ហើយវាយខ្លួនត្រូវទ្រូង ដោយដេកពេទ្យ ១ ថ្ងៃ នៅគ្លីនិកផ្សារបឹងឈូកពេលចេញមកទៅដេកពេទ្យគ្លីនិកសុខភាព ១ យប់ និងព្យួរសេរ៉ូមនៅផ្ទះ ព្យាបាលអស់- ប្រាក់ប៉ុន្មានខ្លួនមិនដឹង ទេព្រោះបងជាអ្នកចេញប្រាក់ ។

- ជនជាប់ចោទ និងជាដើមបណ្ដឹងឈ្មោះ [redacted] បានឆ្លើយថា : ព្យាបាលប្អូនសរុបអស់ជាង ១.០០០.០០០៖០០ ( មួយលានរៀល ) ថ្ងៃកើតហេតុខ្លួន កំពុងចងអង្រឹងដេកស្រាប់តែ ពូឈ្មោះ [redacted] ជេរ ថាអាសេកហ្វៀងជេរកូនអញហ្វៀងខ្លាំងចេញមក ពេលនោះពូខ្លួនកំពុងហូបបាយ ហើយគាត់ចេញទៅ ឈ្មោះ [redacted] ខ្លួនក៏បានជួយឃាត់ ដោយខ្លួនមិនបានវៃគេវិញទេ ខ្លួនឃើញឈ្មោះ [redacted] កូនរបស់គាត់ និងស្រី ខារ៉ាអូខេមកវាយបងខ្លួន១មិនបានវាយ និងជេរគេទេ ។

នៅថ្ងៃកើតហេតុខ្លួនអង្គុយលេងនៅផ្ទះគេទល់មុខផ្ទះឈ្មោះ [redacted] ហើយពូខ្លួនមកហៅអោយហូប បាយ ហើយជេរខ្លួនថាមីគេបាញ់ស៊ើណាបានទៅផ្ទះ ស្រាប់តែឈ្មោះ [redacted] យកបំពង់ទឹបបុកទ្រូងម៉ឹងខ្លួន- ខ្លួនមិនបានវាយគេវិញទេ ហើយខ្លួនបានទូរស័ព្ទហៅប៉ូលីសបកពេលកំពុងតែចុចទូរស័ព្ទស្រាប់តែកូនរបស់គាត់ , ក្មួយគាត់ និងស្រីខារ៉ាអូខេមកខ្វេះមុខ និងជិះលើខ្លួន និងវាយក្បាលខ្លួន ព្យាបាលសរុបជាមួយប្អូនអស់ប្រហែល ២.០០០.០០០៖០០( ពីរលានរៀល ) ខ្លួនប្ដឹងទារពីឈ្មោះ [redacted] កូនគាត់ , ក្មួយគាត់ និងស្រីខារ៉ាអូខេ ។

- ជនជាប់ចោទ និងជាដើមបណ្ដឹងឈ្មោះ [redacted] បានឆ្លើយថា : ថ្ងៃកើតហេតុខ្លួនមកពីរត់- ឡានវិញចូលផ្ទះ ប្រហែលម៉ោង ៩ ល្ងាចខែកញ្ញា គេកំពុងអង្គុយផឹកស៊ីនៅខាងមុខផ្ទះខាងខ្លួន១ កំពុងដេក អង្រឹងស្រាប់តែឈ្មោះ [redacted] បានយកកូនស្រីខ្លួនជាកូនក្មេងចោល ខ្លួនចេះតែអង្គុយស្ដាប់ហើយ ពូនិយាយ- ដដែល១ថាកូនអាញ៉ឹងបានតែគេចុយម្ដាយ ហើយខ្លួនបានដើរទៅសួរនាំ គេក៏ជេរខ្លួន និងវាយខ្លួនដោយមិនដឹង ថាអ្នកណាវាយខ្លួនទេព្រោះគ្នាច្រើនតែឈ្មោះ [redacted] ឲ្យប្រពន្ធវាត់វាយកូនស្រីខ្លួន ។

ខ្ញុំប្ដឹងទាមទារថ្លៃបាត់គ្រឿងអលង្ការកូន ថ្លៃព្យាបាលកូន និងជំងឺចិត្តពីឈ្មោះ [redacted] ចំនួន ៧.000.000៛00 ( ប្រាំពីរលានរៀល ) ។

តាំងពីកើតហេតុមកខ្ញុំឈប់នៅទីនោះហើយ គឺនាំប្រពន្ធកូនទៅនៅនាវិញ ឈប់លក់ដូរទុកដីចោល ។ ខ្ញុំមិនបានវាយគេទេ គ្រាន់តែទៅដល់គេមកព្រួ កូនស្រីខ្ញុំ និងខាងគេខ្ទាចគ្នាមែន គឺខ្ទាចគ្នា-ទៅវិញទៅមក ខ្ញុំក៏ចង់បញ្ចប់រឿងដែរ សុំអោយចំនួន ៧00.000៛00 ( ចិតសិបម៉ឺនរៀល ) ។

- ជនជាប់ចោទឈ្មោះ [redacted] នឆ្លើយថា : ខ្ញុំមិនបានវាយគេទេគ្រាន់តែបានជួយឃាត់ ។

- ជនជាប់ចោទ និងជាដើមបណ្ដឹងឈ្មោ [redacted] នឆ្លើយថា : ពេលប្ដីមកពីរត់ម៉ូតូឌុប-ខ្ញុំរៀបបាយអោយគាត់ហូប មិនទាន់បានហូបបាយផង ស្រាប់តែកូនរបស់គាត់ និងគាត់មករុសទាញប្ដីខ្ញុំទៅពេលនោះខ្ញុំចេញមកកូនស្រីរបស់គាត់ ២ នាក់ និងស្រីខាភ័អូខេបានចាប់ខ្ញុំវាយ ដោយខ្ញុំមិនបានវ៉ៃគេវិញទេកន្លងមកមិនធ្លាប់មានទំនាស់គ្នាទេ នៅពេលនេះខ្ញុំប្ដឹងទារពីឈ្មោះ [redacted] ចំនួន ៧.000.000៛00 ( ប្រាំពីរលានរៀល ) ។

តាំងពីមានទំនាស់មកមិនដែលមានទំនាស់អ្វី និងគ្នាទៀតទេ ។

- សាក្សីឈ្មោះ [redacted] បានឆ្លើយថា : នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោងប្រហែល ១០ យប់ ពេលខ្ញុំកំពុងដេកស្រាប់តែ ឮសំលេងឈ្លោះគ្នា ហើយខ្ញុំបានចេញមកឃាត់ពេលនោះឃើញប្រតាយប្រតប់គ្នាទៅវិញទៅមក មានដំបងមានគុបកែវឈ្មោះ [redacted] ខ្ញុំឃើញចេញឈាមមុខមិនដឹងត្រូវ នឹងអ្វីទេ ខាងក្រុ [redacted] ដូចមិនឃើញមានរបួសអ្វីទេ ខ្ញុំមិនដឹងគេឈ្លោះគ្នារឿងអ្វីទេ ឈ្លោះគ្នាប្រហែលកន្លះម៉ោង មួយម៉ោងក្រោយទើបមានសមត្ថកិច្ចចុះទៅ ២ នាក់ ក្រោយកើតឈ្មោះ [redacted] ត្រូវដឹកទៅមន្ទីរពេទ្យ ។

ខ្ញុំមិនដឹងថាគ្រួសារទាំងពីរធ្លាប់មានទំនាស់គ្នា វីរត់ទេ ថ្ងៃកើតហេតុមិនដឹងថាអ្នកណាជេរអ្នកណាមុនទេ គ្រាន់តែខ្ញុំ ឮខាង [redacted] ជេរថាហ្វៃងមិនបានខ្ញុំកញ្ជះ ឮសូរតែប៉ុណ្ណឹងខ្ញុំក៏ឃាត់ បើកទ្វា-របងមុនដំបូង ឃើញប្រតាយគ្នាក្បៀនពងទឹក មិនដឹងថាអ្នកណាវាយអ្នកណាមុនទេព្រោះពេលនោះងងឹត គ្រាន់តែឃើញស្រី១ ៣-៤ នាក់ ជិះលើភាគីខា [redacted] ាងឈ្មោះ [redacted] មិនឃើញមានកាន់អ្វីទេ ឃើញតែឈរអោបដៃ ពេលស្ងាត់ហើយ ភាគីខាង [redacted] រទៅផ្ទះឃើញកាន់កែវក៏គុបកែវចូលផ្ទះ [redacted] ពេលនោះឃើញ [redacted] កាន់ខ្សែក្រវ៉ាត់មែន តែមិនបានឃើញវាយអ្នកណាទេ ។

- សាក្សីឈ្មោ [redacted] ានឆ្លើយថា : នៅថ្ងៃកើតហេតុខ្ញុំ ឮ សូរមាត់ឈ្លោះប្រកែកគ្នាក៏ចេញទៅមើលឃើញភាគីទាំងពីរឈ្លោះប្រកែកគ្នា និងប្រតាយប្រតប់គ្នា និងជេរប្រមាថគ្នាទៅវិញទៅមក ខ្ញុំក៏ឃាត់ហើយក៏បែកគ្នា ឃើញភាគី [redacted] បកែវចូលផ្ទះ [redacted] ន្លងមកភាគីទាំងពីរមិនដឹងថាមាន-ទំនាស់អ្វី និងគ្នាទេ ។

ពេលកើតហេតុដំបូងខ្ញុំនៅក្នុងផ្ទះ ឮសូរជេរគ្នា តែមិនដឹងអ្នកណាជេរអ្នកណាមុនទេ គឺឮតែមាត់ស្រី១ជេរនូវពាក្យអាក្រក់ តែមិនចាំពាក្យទេព្រោះយូរហើយ ចាំតែពាក្យម៉ែងហង១ ខ្លាំងអី ពេលប្រតាយប្រតប់គ្នា ឃើញខាង [redacted] មានគ្នាច្រើនជាង ឃើ [redacted] ានរបួស ដោយឈ្មោះ [redacted] វាយ ពេលប្រតាយប្រតប់ ឃើញខាង [redacted] កាន់ដំបងក្រោយកើតហេតុឃើញខាង [redacted] គុបកែវចូលទៅមុខផ្ទះ [redacted] មិនបានឃើញអ្នកណាត្រូវរបួសទេ ឈ្លោះគ្នាប្រហែល ២០ នាទី ។

- បានអានចំលើយរបស់ឈ្មោះ [redacted]
- បានអានចំលើយរបស់ឈ្មោះ [redacted]
- បានអានវិញ្ញាបនប័ត្រពេទ្យរបស់ឈ្មោះ [redacted]
- បានអានវិញ្ញាបនប័ត្រពេទ្យរបស់ឈ្មោះ [redacted]



Scanned by CamScanner

- បានអានវិញ្ញាបនប័ត្រពេទ្យរបស់ឈ្មោះ [redacted]

សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ៤៦ ឆ្នាំ ( មានសាវតា- [redacted] ភេទស្រី អាយុ ៤១ ឆ្នាំ ( មានសាវតា [redacted] ភេទស្រី អាយុ ១៩ ឆ្នាំ ( មានសាវតា ) [redacted] ភេទស្រី អាយុ ២២ ឆ្នាំ ( មានសាវតា) [redacted] ភេទស្រី អាយុ ១៩ ឆ្នាំ ( មានសាវតា ). [redacted] ភេទស្រី អាយុ ៣២ ឆ្នាំ ( មានសាវតា) [redacted] ភេទប្រុស អាយុ ៣៥ ឆ្នាំ ( មានសាវតា [redacted] ភេទស្រី អាយុ ២២ ឆ្នាំ ( មានសាវតា [redacted] ភេទស្រី អាយុ ១៨ ឆ្នាំ ( មានសាវតា ) និងឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ ឆ្នាំ ( មានសាវតា ) ពីបទបង្ករបួសដោយចេតនាមានអាវុធ និងជេរ ប្រមាថប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមមាត្រា ៤១ និងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល សូមរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៨៦ ដសសព ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ ដដែល និងសូមលោកចៅក្រមកំណត់ទោសតាមច្បាប់ ។

សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] សុំអោយតុលាការលើកលែងទោស ។

ក្រោយពីបានស្តាប់

- ចម្លើយរបស់ជនជាប់ចោទ និងជាដើមបណ្តឹង
- ចម្លើយសាក្សី
- ការអានចម្លើយជនជាប់ចោទអវត្តមាន
- ការអានវិញ្ញាបនប័ត្រពេទ្យ
- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- សំណូមពររបស់ជនជាប់ចោទ
- ពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការ ខេត្តបាត់ដំបង**

**យល់ឃើញថា**

- ឆ្លងតាមរយៈសវនាការនេះពុំមានភស្តុតាងចួនល្មមអាចអោយតុលាការកំណត់បានថាជនជាប់ចោទឈ្មោះ [redacted] បានប្រព្រឹត្តអំពើជេរប្រមាថ-ដូចមានចែងនៅក្នុងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលឡើយ ដូច្នេះផ្អែកតាមមាត្រា ៣៨ វាក្យខ័ណ្ឌទី ៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គប្បីតុលាការសំរេចអោយជនជាប់ចោទទាំង ៥ នាក់ខាងលើនេះ-រួចផុតពីបទចោទ ។

- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់អាចអោយតុលាការកំណត់បានថាជនជាប់ចោទឈ្មោះ- [redacted] បានប្រព្រឹត្តអំពើបង្ករបួសស្នាមដោយចេតនាមានអាវុធ រីឯជនជាប់ចោទ [redacted] ក្រៅពីប្រព្រឹត្តបទល្មើសបង្ករបួសដោយចេតនាមានអាវុធនៅបានប្រើពាក្យជេរប្រមាថគ្នាដែលបំពានលើមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលទៀតផង ដូច្នេះគប្បីតុលាការផ្តន្ទាទោសជនជាប់ចោទទាំងនេះ តាមមាត្រាច្បាប់ដែលពួកគេម្នាក់ៗបានបំពាន ។

- ការប្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី [redacted] និង [redacted] ពុំមានភស្តុតាងបញ្ជាក់ពីការខូចខាតអោយបានច្បាស់លាស់ ពុំអាចអោយតុលាការលើកយកមកពិចារណាបានទេ លើកលែងតែការខូចខាតរបស់ [redacted] ដែលមានភស្តុតាងបញ្ជាក់ពីការរបួស-

ស្នាមពិតប្រាកដ ដែលបង្កឡើងដោយជនជាប់ចោទ[redacted]គប្បីតុលាការលើកយកពិចារណា និងសំរេច ។

- ជនជាប់ចោទភាគច្រើនទើបប្រព្រឹត្តបទល្មើសជាលើកដំបូង ពុំមានពិការភាពធ្ងន់ធ្ងរ .ទើបប្រព្រឹត្តបទល្មើសជាលើកដំបូង គប្បីតុលាការលើកយកទោសព្យួរមកអនុវត្ត លើកលែងតែ[redacted]ម្នាក់គត់ដែលប្រព្រឹត្តបទល្មើសក្នុងរយៈពេលសាកល្បងពុំអាចអោយតុលាការព្យួរទោសបានឡើយ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការមានពេលសវនាការត្រឹមត្រូវទៅតាមទម្រង់ និងនីតិច្បាប់ លើកលែងតែការតម្កល់បទចោទលើ[redacted]ពីបទជេរប្រមាថដែលគប្បីតុលាការសំរេចអោយរួចពីបទចោទព្រោះគ្មានភស្តុតាងគ្រប់គ្រាន់ ។

- ជនជាប់ចោទ[redacted]សុទ្ធតែសំណូមពរសុំអោយតុលាការលើកលែងទោស តែតុលាការពុំអាចលើកលែងទោសបានទេ ។

**ហេតុដូច្នេះ**

**<u>សំរេច</u>**

១/- អោយជនជាប់ចោទឈ្មោះ

ក-[redacted]ភេទប្រុស អាយុ ៤៦ ឆ្នាំ សញ្ជាតិខ្មែរ ។

ខ-[redacted]ភេទស្រី អាយុ ៤១ ឆ្នាំ សញ្ជាតិខ្មែរ ។

គ[redacted] ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ ។

ឃ[redacted]ភេទស្រី អាយុ ១៨ ឆ្នាំ សញ្ជាតិខ្មែរ ។

ង-[redacted] ហៅ ពៅ ភេទស្រី អាយុ ៣២ ឆ្នាំ សញ្ជាតិខ្មែរ ។

រួចផុតពីបទជេរប្រមាថប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។

បទល្មើសច្បាប់ព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៨៦ ដសសព ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង និងតាមដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១០៣២ ពសព្រទ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្តបាត់ដំបង ។

តាមមាត្រា ៣៨ វាក្យខ័ណ្ឌទី ៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

២/- ផ្តន្ទាទោសលើជនជាប់ចោទ :

ក-[redacted]ភេទស្រី អាយុ ៤១ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣ ខែ ( បីខែគត់ ) និងកែប្រែទោសព្យួរ ១០ ខែ (ដប់ខែ) តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៤០ "ច" ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៤ របស់តុលាការខេត្តបាត់ដំបងទៅជាទោសដាក់ពន្ធនាគារ ។

សរុបទោស ពីដាក់ពន្ធនាគារសរុប ១៣ ខែ ( ដប់បីខែគត់ ) គិតពីថ្ងៃទទួលរងទោសក្នុងពន្ធនាគារ ។

ខ-[redacted]ភេទប្រុស អាយុ ៤៦ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៦ ខែ( ប្រាំមួយខែគត់ ) ប៉ុន្តែទោសនេះត្រូវព្យួរ ។

គ-[redacted] ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ ខែ( បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

ឃ-[redacted]ភេទស្រី អាយុ ១៨ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣ ខែ ( បីខែគត់ ) ប៉ុន្តែទោសនេះត្រូវព្យួរ ។

ង-[redacted] ហៅ ពៅ ភេទស្រី អាយុ ៣២ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ ខែ ( បួនខែគត់ ) ប៉ុន្តែទោសនេះត្រូវព្យួរ ។



Scanned by CamScanner

រយៈពេលសាកល្បង ៥ ឆ្នាំគត់ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

ពីបទបង្ករបួសដោយចេតនាមានអាវុធ ។

៣/- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ

ក-[redacted]ហៅ សេក ភេទប្រុស អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារសរុប ៦ ខែ ( ប្រាំមួយខែគត់ ) ។ ប៉ុន្តែទោសនេះត្រូវព្យួរ ។

ខ- [redacted] ភេទប្រុស អាយុ ១៧ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ ខែ ( បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

គ-[redacted]ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារកំណត់៤ ខែ( បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

ឃ- [redacted]ភេទស្រី អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារសរុបកំណត់ ៣ ខែ( បីខែគត់ )ប៉ុន្តែទោសនេះត្រូវព្យួរ ។

ង-[redacted] ភេទស្រី អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរឥស្លាម ។ ដាក់ពន្ធនាគារសរុប ៣ ខែ ( បីខែគត់ ) ប៉ុន្តែទោសនេះត្រូវព្យួរ ។

រយៈពេលសាកល្បង ៥ ឆ្នាំគត់គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

ពីបទបង្ករបួសដោយចេតនាមានអាវុធ និងជេរប្រមាថប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។

បទល្មើសច្បាប់ព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា ៤១ និង ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសក្នុងបទឧក្រិដ្ឋ ។

៤/- បង្គាប់អោយជនជាប់ចោទឈ្មោះ [redacted]រួមគ្នាសងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តសរុប ២.000.000រ00 ( ពីរលានរៀលគត់ )ទៅអោយនាង[redacted]សំណូមពរលើសពីនេះត្រូវបដិសេធចោល ។

៥/- ពេលសាលក្រមចូលជាស្ថាពរ បើជនជាប់ចោទឈ្មោ[redacted]រួសពុំព្រមបង់ប្រាក់សំណងចំនួន ២.000.000រ00 ទៅអោយដើមបណ្តឹងឈ្មោះ[redacted]ទេនោះ ត្រូវដាក់គុកបង្ខំដល់រូបរាងកាយក្នុងម្នាក់១ពីរឆ្នាំ ដើម្បីបង្ខំទារប្រាក់ធនភ័ណ្ឌតាមមាត្រា ៧ និង ៨ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបរាងកាយក្នុងរឿងព្រហ្មទ័ណ្ឌ ។

៦/- សាលក្រមនេះជំនុំជំរះចំពោះមុខជនជាប់ចោទឈ្មោ[redacted]ក់បាំងមុខជនជាប់ចោទ[redacted] ។

បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និង ត្រា : [redacted]

ចៅក្រមជំនុំជំរះ

ហត្ថលេខា និងត្រា[redacted]

---

បានយើញ

...បាត់ដំបង .ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧

ចៅក្រម

[redacted]

បានវាយចម្លងត្រឹមត្រូវតាមសាលក្រមដើម

បាត់ដំបង ... ២០ ខែ មិថុនា ឆ្នាំ ២០០៧

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner